សមាគមអាដហុក
ADHOC

## របាយការណ៍ស្តីពី

# ទិន្នន័យតាមដានករណីអំពើហិង្សាទាក់ទង នឹងយេនឌ័រ នៅក្នុងប្រទេសកម្ពុជា



ខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥

# របាយការណ៍ស្តីពី
# ទិន្នន័យតាមដានករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងប្រទេសកម្ពុជា
# ខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥

**ទិដ្ឋភាពទូទៅ៖** របាយការណ៍នេះបង្ហាញពីទិន្នន័យដែលប្រមូលបាន និងតាមដានដោយសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) ក្នុងអំឡុងពេលនៃការតាមដានលើករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាពិសេសករណីរំលោភសេពសន្ថវៈ (ជនរងគ្រោះជាអនីតិជន) និងអំពើហិង្សាក្នុងគ្រួសារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា («កម្ពុជា») ចន្លោះពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥។ បន្ថែមពីនេះ សមាគមអាដហុកបានប្រៀបធៀបទិន្នន័យរវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ដើម្បីមើលថាតើមានវឌ្ឍនភាពដែរ ឬទេ។

នៅឆ្នាំ២០២៤ សមាគមអាដហុកតាមដាន និងឃ្លាំមើលករណីរំលោភសេពសន្ថវៈ និងហិង្សាក្នុងគ្រួសារ តាមរយៈបុគ្គលិកប្រចាំនៅការិយាល័យស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តសរុបចំនួន២៣ រាជធានី/ខេត្ត និងនៅឆ្នាំ២០២៥ តាមរយៈបុគ្គលិកប្រចាំការិយាល័យចំនួន១៣ រាជធានី/ខេត្ត។

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់និយមន័យអំពើហិង្សាទាក់ទងនឹងយេនឌ័រថាជា «អំពើហិង្សាដែលសំដៅទៅលើស្ត្រី ដោយសារតែនាងជាស្ត្រី ឬអំពើហិង្សាដែលជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ (មិនសមាមាត្រ) ទៅលើស្ត្រី»។ បញ្ហានេះនៅតែជាការប្រឈមដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ បានរកឃើញថា ស្ត្រីកម្ពុជាដែលមានអាយុចន្លោះពី ១៥ ដល់ ៤៩ ឆ្នាំ ជាង ២១% បានជួបប្រទះនូវអំពើហិង្សាពីដៃគូជិតស្និទ្ធ។

សមាគមអាដហុក តាមដាន និងឃ្លាំមើលករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគោលបំណង៖

(១) ដើម្បីតាមដានវឌ្ឍនភាពនៃអនុសាសន៍នានារបស់ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី របស់រាជរដ្ឋាភិបាលកម្ពុជា។

(២) ដើម្បីស្វែងយល់ពីការទទួលបាន និងប្រសិទ្ធភាពនៃសេវាកម្មរបស់សមាគមអាដហុក ហើយនៅពេលរាយការណ៍អំពីទិន្នន័យ គឺដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីសេវាកម្មនានាដែលសមាគមអាដហុកបានផ្តល់ជូន។ និង

(៣) ដើម្បីទទួលបាននូវសញ្ញាបង្ហាញថា តើបទដ្ឋានសង្គមពាក់ព័ន្ធនឹងការទទួលយកអំពើហិង្សាលើស្ត្រី កំពុងត្រូវបានដោះស្រាយ (ការប្រឈម) និងកំពុងតែធ្លាក់ចុះនៅក្នុងសង្គមទាំងមូលដែរ ឬទេ។

**កំណត់ចំណាំ៖** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។

**នៅឆ្នាំ២០២៥ អង្គការសមាគមអាដហុក បានឃ្លាំមើលករណីរំលោភសេពសន្ថវៈចំនួន១២២ ករណី និង ករណីអំពើហិង្សាក្នុងគ្រួសារចំនួន៧៥ ករណី សរុបចំនួន១៩៧ ករណី។**

## តើនរណាខ្លះដែលរាយការណ៍មកអាដហុកចំពោះករណីទាំងនេះ?




ជារវឌ្ឍនភាពដ៏ល្អមួយ ដែលអ្នកផ្ដល់ព័ត៌មានភាគច្រើន គឺជាជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេផ្ទាល់។ កាលពីអតីតកាល **"មូលហេតុចម្បងដែលនាំឱ្យ (ស្ត្រី) មិនស្វែងរកជំនួយ គឺដោយសារតែពួកគេគិតថាអំពើហិង្សានោះជារឿងធម្មតា"**។ នេះបង្ហាញថា ផ្នត់គំនិតបែបនេះកំពុងតែមានការផ្លាស់ប្ដូរហើយ។

## តើអ្វីជាមូលហេតុចម្បងដែលនាំឱ្យករណីទាំងនេះកើតឡើង?




**កំណត់ចំណាំ៖** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។




របាយការណ៍ “**ការវិភាគទិន្នន័យបន្ថែមស្តីពីអំពើហិង្សាក្នុងគ្រួសារ ផ្អែកលើអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២**” បានផ្តល់អនុសាសន៍ឱ្យរាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) ដោះស្រាយបញ្ហាការសេពគ្រឿងស្រវឹងហួសកម្រិត ដោយសារបានធ្វើឱ្យអត្រានៃអំពើហិង្សាផ្អែកលើយេនឌ័រកាន់តែធ្ងន់ធ្ងរឡើង។ “**ស្ថានភាពស្រវឹង**” ត្រូវបានរកឃើញថាជាកត្តាជំរុញខ្ពស់បំផុតដែលបង្កឱ្យមានអំពើហិង្សាក្នុងគ្រួសារ និងជាកត្តាខ្ពស់បំផុតទីពីរដែលនាំឱ្យមានអំពើរំលោភសេពសន្ថវៈ ដែលនេះបង្ហាញថា បញ្ហាមួយនេះត្រូវតែដោះស្រាយជាអាទិភាពខ្ពស់បំផុត។

អនុសាសន៍មួយទៀតដែលមើលទៅពិតជាត្រូវការការប្តេជ្ញាចិត្តខ្ពស់នោះគឺ ការលើកកម្ពស់លក្ខណៈបុរសបែបអហិង្សា ពោលគឺអារម្មណ៍ដូចជា ការមិនអត់ធ្មត់ ការប្រចណ្ឌ និងភាពតានតឹង (ស្ត្រេស) មិនគួរត្រូវបានយកមកបញ្ចេញ ឬទម្លាក់កំហុសលើស្ត្រីនោះទេ។

ទោះជាយ៉ាងណាក៏ដោយ នោះជាសញ្ញាវិជ្ជមានមួយដែលមូលហេតុត្រូវបានរកឃើញថា មិនមែនជាការបន្ទោសខ្លួនឯងនោះទេ។ ការបន្ទោសជនរងគ្រោះ គឺជាឧបសគ្គដ៏ធំមួយក្នុងការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងប្រទេសកម្ពុជា។ ការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេមើលឃើញថាជា **«រឿងត្រឹមត្រូវ»** នៅពេលដែលមានការបំពានលើបទដ្ឋានយេនឌ័រ ដូចជា រឿងម្ហូបអាហារ ការបំពេញតម្រូវការផ្លូវភេទ និងការមិនស្តាប់បង្គាប់ ជាដើម (Brickell, 2017)។

**អត្តសញ្ញាណយេនឌ័រ និងជីវភាពរបស់ជនរងគ្រោះ**

ករណីដែលត្រូវបានតាមដានដោយសមាគមអាដហុក ពុំបានបង្ហាញពីការផ្លាស់ប្តូរណាមួយនៅក្នុងនិន្នាការដែលថា ស្ត្រី និងអ្នកមានជីវភាពក្រីក្រ គឺជាជនរងគ្រោះញឹកញាប់បំផុតនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនោះឡើយ។

**កំណត់ចំណាំ៖** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។

## ស្ថានភាពជីវភាព







## អត្តសញ្ញាណយេនឌ័រ







## អត្តសញ្ញាណយេនឌ័ររបស់ជនប្រព្រឹត្ត

- និន្នាការដែលអ្នកប្រព្រឹត្តភាគច្រើនលើសលប់ជាបុរស ក៏នៅតែបន្តកើតមានក្នុងឆ្នាំ២០២៥ ផងដែរ។
- មិនមានអ្នកប្រព្រឹត្តណាម្នាក់ជាអ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ+) នោះឡើយ។







## ស្ថានភាពរបស់ជនរងគ្រោះក្រោយពេលកើតហេតុ

អំពើហិង្សាពីដៃគូជិតស្និទ្ធ គឺជាបញ្ហាសុខភាពសាធារណៈដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានេះមិនត្រូវបានគេយកចិត្តទុកដាក់ និងដោះស្រាយក្នុងកម្រិតបែបនោះជានិច្ចកាលឡើយ។ ការអង្កេតសុខភាពកម្ពុជាបានរកឃើញថា នៅពេលដែលស្ត្រីស្វែងរកជំនួយដោយសារអំពើហិង្សា ពួកគេកម្រនឹងត្រូវបានបញ្ជូនទៅជួបបុគ្គលិកសុខាភិបាលណាស់ ដោយសារតែអំពើហិង្សាត្រូវបានគេចាត់ទុកថាជារឿងធម្មតា។

ចន្លោះឆ្នាំ២០២០ ដល់ខែសីហា ឆ្នាំ២០២៥ អង្គការលីកាដូ (LICADHO) បានកត់ត្រាទុកនូវករណីឃាតកម្មចំនួន ១៤៦ ករណី ដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ដែលក្នុងនោះរួមមានស្ត្រីចំនួន ៩៦ នាក់ និងកុមារចំនួន ៤៦ នាក់។ ដូចដែលអង្គការលីកាដូបានទទួលស្គាល់ ចំនួនពិតប្រាកដប្រហែលជាអាចខ្ពស់ជាងនេះទៅទៀត ដោយសារតែមានករណីជាច្រើនមិនត្រូវបានរាយការណ៍ ឬមិនត្រូវបានស៊ើបអង្កេត។

**កំណត់ចំណាំ៖** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។







លើសពីនេះទៅទៀត មានជនរងគ្រោះនៃករណីរំលោភសេពសន្ថវៈដែលបានឃ្លាំមើលតែម្នាក់គត់ដែលទទួលបានសំណង។ នេះឆ្លុះបញ្ចាំងពីបញ្ហាមួយចំនួននៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា។ ច្បាប់មិនបានចែងច្បាស់លាស់អំពីចំនួនទឹកប្រាក់សំណងដែលគួរតែត្រូវបានបង្គាប់ឱ្យសងនោះទេ។ ប្រសិនបើអ្នកប្រព្រឹត្តមិនព្រមបង់ប្រាក់សំណងរដ្ឋប្បវេណីដែលជំពាក់នោះទេ គឺដើមបណ្ដឹងរដ្ឋប្បវេណីមានភារកិច្ចខ្លួនឯងក្នុងការផ្ដួចផ្ដើមឱ្យមានការអនុវត្តច្បាប់ (និងត្រូវឆ្លងកាត់បន្ទុកនៃការស្វែងរកភស្តុតាងដ៏ធ្ងន់ធ្ងរ)។ ការទាមទារសំណងអាចបង្កជាជម្លោះកាន់តែខ្លាំង ឬមិនទទួលបានលទ្ធផលអ្វីឡើយ នៅពេលដែលអ្នកប្រព្រឹត្តគឺជាសមាជិកនៅក្នុងគ្រួសាររបស់ជនរងគ្រោះផ្ទាល់ (ករណីបែបនេះកើតមានជាញឹកញាប់) ហើយវាទាមទារឱ្យជនរងគ្រោះត្រូវប្ដឹងផ្ដល់ក្នុងសំណុំរឿងរដ្ឋប្បវេណីដាច់ដោយឡែកមួយទៀត ដែលនេះនាំឱ្យមានបន្ទុកលើការចំណាយ ការធ្វើដំណើរ និងធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តសារជាថ្មី។

## ស្ថានភាពរបស់អ្នកប្រព្រឹត្តក្រោយពេលកើតហេតុ

មានវឌ្ឍនភាពវិជ្ជមានមួយ គឺការកើនឡើងនូវទណ្ឌកម្ម (ផលវិបាកផ្លូវច្បាប់) ចំពោះអ្នកប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ។







**កំណត់ចំណាំ៖** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។

នៅពេលប្រៀបធៀបប្រភេទបទល្មើសទាំងពីរ ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការរបស់សមត្ថកិច្ចអនុវត្តច្បាប់ ដែលស្មើនឹងប្រហែល ៤៧% នៃលទ្ធផលក្នុងករណីរំលោភសេពសន្ថវៈ និង ៤២% ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ។ ទោះជាយ៉ាងណាក៏ដោយ ជនល្មើសនៃអំពើហិង្សាក្នុងគ្រួសារមានអត្រានៅមានសេរីភាពក្រោយពេលកើតហេតុខ្ពស់ជាង (ជិត ១០%) បើប្រៀបធៀបទៅនឹងជនល្មើសនៃករណីរំលោភសេពសន្ថវៈ (តិចជាង ៦%)។

## ការមិនដាក់ពាក្យបណ្តឹង និងមូលហេតុចម្បងៗ

ក្នុងចំណោមករណីដែលបានកត់ត្រាទុកសរុប មាន១១ ករណីដែលជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹងជាផ្លូវការទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ដែលក្នុងនោះរួមមាន ករណីរំលោភសេពសន្ថវៈ ៥ ករណី និងករណីអំពើហិង្សាក្នុងគ្រួសារ ៦ ករណី។




ឧបសគ្គដ៏ធំបំផុតដែលនាំឱ្យមានការមិនរាយការណ៍ គឺការខ្វះជំនឿទុកចិត្តលើស្ថាប័នអនុវត្តច្បាប់ ដោយក្នុងនោះមាន ជនរងគ្រោះ ៤ នាក់បានបញ្ជាក់យ៉ាងច្បាស់ថា ពួកគេមិនមានជំនឿចិត្តលើអាជ្ញាធរ ក្នុងការដោះស្រាយ ឬមានចំណាត់ការលើករណីរបស់ពួកគេឡើយ។

ការភ័យខ្លាច និងបំណងប្រាថ្នាក្នុងការទប់ស្កាត់កុំឱ្យមានជម្លោះរីករាលដាលបន្តទៀត បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យជនរងគ្រោះរក្សាភាពស្ងៀមស្ងាត់។ ក្នុងនោះ ជនរងគ្រោះ ២ នាក់បានសម្រេចចិត្តមិនប្តឹងដោយសារខ្លាចមានការសងសឹក ខណៈដែល ២ នាក់ទៀតបានលើកឡើងថា ពួកគេគ្រាន់តែមិនចង់ឱ្យមានបញ្ហាកាន់តែវែងឆ្ងាយ ពីហេតុការណ៍នោះ។

ការមិនស្វែងរកការអន្តរាគមន៍តាមផ្លូវច្បាប់ចំនួន១ករណី ដោយសារតែភាគីពាក់ព័ន្ធកំពុងស្ថិតក្នុងដំណាក់កាលចរចារសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ ខណៈដែល ២ ករណីដែលនៅសេសសល់ គឺបណ្តាលមកពីមូលហេតុផ្សេងៗ ដែលមិនបានបញ្ជាក់លម្អិត។

ទិន្នន័យនេះបានបង្ហាញឱ្យឃើញថា ជិត ៣៦% នៃជនរងគ្រោះដែលមិនបានដាក់ពាក្យបណ្តឹង គឺដោយសារតែការខ្វះជំនឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌។ នៅពេលបូករួមបញ្ចូលជាមួយការភ័យខ្លាចចំពោះការសងសឹក ឬការមិនចង់ឱ្យមានបញ្ហាស្មុគស្មាញបន្តទៀត ការខ្វះជំនឿចិត្តលើស្ថាប័ន និងក្តីបារម្ភផ្នែកសុវត្ថិភាព បានក្លាយជាជញ្ជាំងរាំងស្ទះចម្បងដែលធ្វើឱ្យជនរងគ្រោះទាំងក្នុងករណីរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារមិនហ៊ានស្វែងរកកិច្ចការពារផ្លូវច្បាប់ជាផ្លូវការ។

**កំណត់ចំណាំ៖** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។

# ការប្រៀបធៀបទិន្នន័យរវាងឆ្នាំ២០២៤ និង២០២៥

ចំនួនសរុបនៃហេតុការណ៍ដែលបានកត់ត្រាទុក មានការធ្លាក់ចុះប្រមាណ២៩% ដោយបានថយចុះពី ២៧៧ ករណីសរុបក្នុងឆ្នាំ២០២៤ មកត្រឹម១៩៧ ករណីសរុបក្នុងឆ្នាំ២០២៥។ និន្នាការធ្លាក់ចុះនេះត្រូវបានឆ្លុះបញ្ចាំងលើប្រភេទបទល្មើសទាំងពីរ ដោយទាំងករណីរំលោភសេពសន្ថវៈ និងករណីអំពើហិង្សាក្នុងគ្រួសារ សុទ្ធតែមានការថយចុះយ៉ាងកត់សម្គាល់នៅឆ្នាំ២០២៥។

| ប្រភេទករណី | ២០២៤ | ២០២៥ | ការប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| រំលោភសេពសន្ថវៈ | ១៧០ | ១២២ | ថយចុះ៤៨ ករណី | ថយចុះប្រមាណ២៨ ភាគរយ |
| ហិង្សាក្នុងគ្រួសារ | ១០៧ | ៧៥ | ថយចុះ៣២ ករណី | ថយចុះប្រមាណ៣០ ភាគរយ |
| **សរុប** | **២៧៧** | **១៩៧** | **ថយចុះ៨០ ករណី** | **ថយចុះប្រមាណ២៩ ភាគរយ** |

ទោះបីជាប្រភេទបទល្មើសនេះនៅតែមានចំនួនច្រើនជាងគេក្នុងចំណោមបទល្មើសទាំងពីរក្នុងរយៈពេលទាំងពីរឆ្នាំក៏ដោយ ករណីរំលោភសេពសន្ថវៈបានធ្លាក់ចុះពី១៧០ ករណី ក្នុងឆ្នាំ២០២៤ មកត្រឹម១២២ ករណីក្នុងឆ្នាំ២០២៥ (ថយចុះអស់ ៤៨ ករណី)។

ករណីអំពើហិង្សាក្នុងគ្រួសារក៏បានបង្ហាញពីការរួញថយផងដែរ ដោយបានធ្លាក់ចុះពី១០៧ ករណីក្នុងឆ្នាំ២០២៤ មកត្រឹម៧៥ ករណីក្នុងឆ្នាំ២០២៥ (ថយចុះអស់ ៣២ ករណី)។

ករណីរំលោភសេពសន្ថវៈមានភាពប្រែប្រួលលឿន និងបានធ្លាក់ចុះក្នុងល្បឿនលឿនជាង បើធៀបនឹងអំពើហិង្សាក្នុងគ្រួសារ។ នេះសញ្ជើញឱ្យឃើញថា អំពើហិង្សាក្នុងគ្រួសារនៅតែជាបញ្ហាដែលចាក់ឫសយ៉ាងជ្រៅ និងពិបាកក្នុងការលុបបំបាត់ជាង ព្រោះវាជាបញ្ហាដែលកើតឡើងនៅពីក្រោយទ្វារបិទជិត និងនៅក្នុងរង្វង់គ្រួសារ ដែលធ្វើឱ្យវាមិនសូវរងឥទ្ធិពលពីវិធានការសន្តិសុខសាធារណៈ ឬវិធានការទប់ស្កាត់ទូទៅឡើយ។ ដូច្នេះ អន្តរាគមន៍នាពេលអនាគតគួរតែតម្រង់ទិសដៅយ៉ាងខ្លាំងក្លាទៅលើ "លំហឯកជន" ដោយផ្តោតលើការបង្កើតកន្លែងមានសុវត្ថិភាពក្នុងកម្រិតសហគមន៍ និងការផ្តល់ប្រឹក្សាដោះស្រាយជម្លោះក្នុងគ្រួសារ ព្រោះអំពើហិង្សាក្នុងគ្រួសារកំពុងបង្ហាញពីភាពស៊ាំ និងភាពស៊ូទ្រាំទៅនឹងយុទ្ធសាស្ត្រកាត់បន្ថយបទល្មើសនាពេលបច្ចុប្បន្ន។

**កំណត់ចំណាំ៖** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។

## សេចក្តីសន្និដ្ឋាន

មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ក្នុងផ្នត់គំនិត និងទម្លាប់សង្គម ដោយជនរងគ្រោះ និងសាច់ញាតិលែងចាត់ទុកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ជាជារឿងធម្មតាទៀតហើយ ប៉ុន្តែពួកគេបានចាប់ផ្តើមរាយការណ៍ពីហេតុការណ៍ទាំងនោះដោយផ្ទាល់ទៅកាន់អាជ្ញាធរ។

ករណីរំលោភសេពសន្ថវៈនៅតែបន្តមានចំណែកធំជាងគេ នៅក្នុងចំណោមករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលត្រូវបានកត់ត្រាទុក ដោយរក្សាចំនួនខ្ពស់ជាងករណីអំពើហិង្សាក្នុងគ្រួសារ ក្នុងរយៈពេលទាំងពីរឆ្នាំ។ បើពិនិត្យជារួម ចំនួនសរុបនៃបទល្មើសទាំងពីរប្រភេទនេះ ឆ្លុះបញ្ចាំងពីបញ្ហាប្រឈមដ៏ធំ និងការបន្តកើតមាននៅក្នុងសង្គម ពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ជាប្រចាំពីស្ថាប័នពាក់ព័ន្ធ។ ទោះជាយ៉ាងណា ស្ត្រី និងប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ នៅតែជាក្រុមងាយរងគ្រោះបំផុត ខណៈដែលបុរសគឺជាអ្នកប្រព្រឹត្តភាគច្រើនលើសលប់។

បើទោះបីជាចំនួនករណីមានការថយចុះក៏ដោយ របាយការណ៍នៅតែបង្ហាញពីបញ្ហាប្រឈមសំខាន់ៗ ដូចជា ការសេពគ្រឿងស្រវឹងហួសប្រមាណដែលជាមូលហេតុចម្បងនៃអំពើហិង្សា ការខ្វះជំនឿទុកចិត្តលើស្ថាប័នអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការភ័យខ្លាចការសងសឹករបស់ជនរងគ្រោះ និងការលំបាកក្នុងការទទួលបានសំណង និងការការពារផ្លូវច្បាប់ ដោយសារតែដំណើរការអនុវត្តនីតិវិធីសំណងរដ្ឋប្បវេណីមានភាពស្មុគស្មាញ និងចំណាយថវិកាច្រើន ទាំងនេះគឺជាការបន្ថែមទម្ងន់ផលប៉ះពាល់ផ្លូវចិត្ត និងសេដ្ឋកិច្ចធ្ងន់ធ្ងរដល់ជនរងគ្រោះមួយកំរិតថែមទៀងផងដែរ។

## អនុសាសន៍

### សម្រាប់រាជរដ្ឋាភិបាលៈ

- ផ្តល់អាទិភាព និងពង្រឹងវិធានការគ្រប់គ្រងការសេពគ្រឿងស្រវឹង ដោយសារការស្រវឹងនៅតែជាមូលហេតុចម្បងនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈធ្ងន់ធ្ងរ។
- អាជ្ញាធរមានសមត្ថកិច្ច ជាពិសេសតុលាការ ត្រូវពង្រឹងចំណាត់ការខាងសំណងរដ្ឋប្បវេណី ដោយធានាថា ជនរងគ្រោះទទួលបានសំណងសមរម្យ យុត្តិធម៌ តាមរយៈការបន្ថយ ឬសម្រួលភាពស្មុគស្មាញខាងនីតិវិធីដែលជាបន្ទុកដល់ជនរងគ្រោះ។
- ពង្រឹងសមត្ថភាព និងគុណភាពរបស់សមត្ថកិច្ចលើការដោះស្រាយបណ្តឹងដោយតម្លាភាព និងយុត្តិធម៌ ព្រមទាំងដាក់វិន័យ ឬទោសទណ្ឌចំពោះសមត្ថកិច្ចណាដែលអនុវត្តច្បាប់មិនបានត្រឹមត្រូវ ដើម្បីកាត់បន្ថយអត្រាខ្វះជំនឿចិត្តរបស់ពលរដ្ឋចំពោះប្រព័ន្ធយុត្តិធម៌ ដែលជាឧបសគ្គរាំងជនរងគ្រោះក្នុងការស្វែងរកយុត្តិធម៌។
- ពង្រីកសេវាសុខភាព និងសេវាគាំទ្រផ្លូវចិត្តសម្រាប់ជនរងគ្រោះ តាមរយៈកិច្ចសហការរវាងវិស័យសុខាភិបាល និងស្ថាប័នច្បាប់។ នាពេលបច្ចុប្បន្ន ជនរងគ្រោះដែលស្វែងរកជំនួយ កម្រនឹងត្រូវបានបញ្ជូនទៅជួបគ្រូពេទ្យ ឬអ្នកជំនាញវេជ្ជសាស្ត្រណាស់ ដោយសារតែរើសអើង និងការខ្មាសអៀនក្នុងសង្គម។
- បង្កើនយុទ្ធនាការផ្សព្វផ្សាយ និងកម្មវិធីអប់រំទូទាំងប្រទេស ដើម្បីកែប្រែផ្នត់គំនិតអវិជ្ជមានពាក់ព័ន្ធនឹងយេនឌ័រ និងកាត់បន្ថយការទទួលយកអំពើហិង្សាលើស្ត្រី។

**កំណត់ចំណាំៈ** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។

**សម្រាប់ភាគីពាក់ព័ន្ធ (អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងមេដឹកនាំសហគមន៍)៖**

- លើកកម្ពស់ឥរិយាបថបុរសដែលគ្មានអំពើហិង្សា៖ វិនិយោគលើកម្មវិធីអប់រំសហគមន៍ដែលបណ្តុះបណ្តាលបុរសឱ្យមានការអត់ធ្មត់ ចរិតលក្ខណៈអហិង្សា និងសមភាពយេនឌ័រ។ ត្រូវផ្តោតលើកត្តាជំរុញខាងផ្លូវចិត្តដូចជា ភាពមិនចេះអត់ធ្មត់ ភាពប្រចណ្ឌ និងភាពតានតឹង (ស្ត្រេស) ដោយសង្កត់ធ្ងន់ថាអារម្មណ៍ទាំងនេះមិនអាចយកមកធ្វើជាលេសដើម្បីប្រើអំពើហិង្សាលើស្ត្រីបានឡើយ។
- តម្រង់ទិសធនធានទៅកាន់ក្រុមងាយរងគ្រោះខ្ពស់៖ ផ្តល់ជំនួយផ្នែកច្បាប់ គាំទ្រផ្នែកសេដ្ឋកិច្ច ការព្យាបាលរាងកាយ និងផ្លូវចិត្ត និងសេវាការពារដោយផ្ទាល់ដល់សហគមន៍ក្រីក្រ និងស្ត្រី ដែលជាក្រុមបន្តរងគ្រោះខ្លាំងជាងគេពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- ពង្រឹងបណ្តាញគាំទ្រក្នុងសហគមន៍៖ ដោយសារតែសាច់ញាតិ និងបណ្តាញមូលដ្ឋានគឺជាអ្នករាយការណ៍ចម្បង ដូច្នេះត្រូវបង្កើនយុទ្ធនាការកសាងការយល់ដឹងនៅមូលដ្ឋានសហគមន៍អំពីរបៀបកត់ត្រាហេតុការណ៍ដោយសុវត្ថិភាព របៀបរាយការណ៍ និងរបៀបការពារជនរងគ្រោះពីការគំរាមកំហែងសងសឹក។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន មណ្ឌលសុខភាព និងមេដឹកនាំសហគមន៍ ដើម្បីពង្រឹងប្រព័ន្ធបញ្ជូនករណី និងសេវាគាំទ្រជនរងគ្រោះ។

**កំណត់ចំណាំ៖** របាយការណ៍នេះឆ្លុះបញ្ចាំងតែទិន្នន័យដែលសមាគមអាដហុក (ADHOC) ប្រមូលបានតែប៉ុណ្ណោះ។ របាយការណ៍នេះពុំមានបំណងបង្ហាញជាលក្ខណៈស្ថិតិ អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ ឬអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅទូទាំងប្រទេសកម្ពុជានោះឡើយ។